# អំពើប្រល័យពូជសាសន៍ដែលអាក្រក់បំផុត
# ចំណាប់អារម្មណ៍របស់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ អេ មូសូមេលី
# ចំពោះអ្នកចូលរួមដំណើរទស្សនកិច្ចមកកាន់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា
# ថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០០៦

សួស្តី ខ្ញុំមានកិត្តិយសសូមស្វាគមន៍អស់លោក លោកស្រី ទាំងអស់គ្នាដែលបានមកកាន់គេហដ្ឋានរបស់ខ្ញុំនៅថ្ងៃនេះ ។ កាលពីប៉ុន្មានខែមុននេះ ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យក៏បានមកអង្គុយនៅកន្លែងដែលអស់លោក លោកស្រីកំពុងអង្គុយនេះដែរ ហើយខ្ញុំបានប្រាប់ពួកគាត់ពីរឿងដែលឧក្រិដ្ឋកម្មធំជាងគេបំផុតមួយនេះប្រចាំសតវត្សរ៍ទី២០ មិនទាន់បានទទួលការជំនុំជម្រះសេចក្តីនៅឡើយអស់រយៈកាល៣០ឆ្នាំមកហើយ ។


ចូសេហ្វ អេ មូសូមេលី
ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក

ដូចយើងបានដឹងរួចហើយក្នុងរយៈកាលចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពោលគឺ មិនដល់រយៈពេល៤ឆ្នាំផង របបខ្មែរក្រហមបានធ្វើទារុណកម្ម បង្អត់អាហារ និងសម្លាប់រង្គាលជនរួមជាតិកម្ពុជារបស់គេអស់ប្រមាណជាង២លាននាក់ ។ គ្មាននរណាម្នាក់មានសុវត្ថិភាពទេ នៅពេលនោះមិនថា ចាម វៀតណាម ព្រះសង្ឃ អ្នករស់នៅទីក្រុង អ្នកមានសញ្ញាប័ត្រ ឬអ្នកដែលពាក់វ៉ែនតា ។ អ្នកទាំងនេះ និងមនុស្សដទៃជាច្រើនទៀត រួមជាមួយនឹងគ្រួសាររបស់គេផង ត្រូវបានសម្លាប់យ៉ាងរង្គាលនៅក្នុងអំពើប្រល័យពូជសាសន៍មួយដែលអាក្រក់បំផុត និងមិនដែលមានពីមុនមក ។

ទោះជាយ៉ាងណាក៏ដោយ អ្នកខ្លះបាននិយាយថា អំពើឧក្រិដ្ឋទាំងនោះកើតឡើងយូរមកហើយ ហើយយើងគួរតែឈប់រំឭកអំពីអតីតកាលនេះ ។ គេនិយាយថា យើងគួរក្រឡេកមើលទៅអនាគតនិងមិនគួរចំណាយថវិកាសន្ធឹកសន្ធាប់បែបនេះទៅលើសាលាជំនុំជម្រះក្តីនេះឡើយ ហើយគេនិយាយទៀតថា ថវិកានេះ គួរតែយកទៅប្រើប្រាស់ដើម្បីទិញស្បៀងអាហារ ឬផ្តល់ការថែទាំសុខភាពដល់អ្នកជំងឺវិញល្អជាង ។ ជាការពិតណាស់អ្នកក្រគួរតែទទួលបានស្បៀងអាហារ ហើយអ្នកឈឺគួរតែទទួលបានការថែទាំសុខភាព ។ តើប៉ុណ្ណឹងគ្រប់គ្រាន់ឬទេ? តើយើងត្រូវការតែប៉ុណ្ណឹងទេឬ? តើរឿងសំខាន់មានតែត្រឹមការស្រេកឃ្លានស្បៀងអាហារទេឬ?

ឃ្លាមួយក្នុងព្រះគម្ពីរសាសនាគ្រីស្តបាននិយាយថា ៖ «មនុស្សមិនមែនរស់ដោយសារតែនំបុ័ងមួយមុខនោះទេ» ។ យើងទាំងអស់គ្នាអាចយល់បានអំពីអត្ថន័យរបស់ឃ្លានេះ ពោលគឺមានន័យថា យើងមិនមែនជាសត្វមួយប្រភេទដែលមានការស្រេកឃ្លានអាហារដូចសត្វធាតុនោះទេ ។ អាហារតែមួយមុខមិនអាចបំពេញការស្រេកឃ្លានរបស់យើងបានទេ ។ មនុស្សគឺជាសត្វលោកដែលមានវិញ្ញាណនិងសីលធម៌ ។ តើមានអ្នកដែលនិយាយថា យើងមិនគួរមានវត្តអារាមទេ? តើមានអ្នកដែលនិយាយថា «យើងគួរតែរុះរើវិហារសាសនាគ្រីស្ត និងវិហារសាសនាអ៊ិស្លាមចេញដើម្បីយកថវិការទាំងនោះទៅផ្គត់ផ្គង់ស្បៀងអាហារដល់អ្នកដែលកំពុងតែស្រេកឃ្លានទៅវិញ»ដែរឬទេ? ភាគច្រើននៃពួកយើងទាំងអស់គ្នាដឹងថា យើងមានការស្រេកឃ្លានផ្នែកផ្លូវចិត្ត ដែលគេគួរតែបំពេញ ហើយយើងដឹងដែរថា វត្តអារាម និងព្រះវិហារគ្រិស្តសាសនាជួយបំពេញការស្រេកឃ្លាននោះ ។

មនុស្សស្រេកឃ្លានអ្វីផ្សេងទៀត យ៉ាងហោចណាស់ក៏សំខាន់ស្មើនឹងអាហារដែរ ។ យើងស្រេកឃ្លានយុត្តិធម៌ ។ យើង

មិនទទួលបានយុត្តិធម៌យូរមកហើយ ។ អំពើប្រល័យពូជសាសន៍នៅកម្ពុជាជាករណីតែមួយគត់ដែលមិនទាន់ឃើញមានការផ្តន្ទាទោសជនដៃដល់ ។ ចាប់តាំងពីការកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ។ ប៉ុន្តែ យុត្តិធម៌របៀបនេះមិនបានកើតមានទេនៅក្នុងប្រទេសកម្ពុជា ។

អ្នកខ្លះលើកឡើងថា ការចំណាយថវិកាដែលកំពុងខ្សត់ទៅលើបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងកាលពី៣០ឆ្នាំមុន គឺជារឿងដែលគួរឲ្យអស់សំណើច ប៉ុន្តែ ខ្ញុំសង្ឃឹមថាប្រជាជនខ្មែរភាគច្រើននឹងមិនយល់ស្របតាមការអះអាងនេះទេ ។ នៅកម្ពុជាអ្នកទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ជាទូទៅ កំពុងរស់នៅដោយមានសុវត្ថិភាពនិងសេរីភាពយ៉ាងសម្បូរសប្បាយនៅក្នុងចំណោមមនុស្សដែលពួកគេធ្វើបាប ។ មិនមានគ្រួសារណាមួយនៅកម្ពុជាដែលមិនរងការប៉ះពាល់ដោយសារអំពើប្រល័យពូជសាសន៍ទេ ។ របបខ្មែរ-ក្រហមបានប្រកាសថា ខ្លួននឹងនាំប្រទេសកម្ពុជាទៅកាន់ “ឆ្នាំសូន្យ” ហើយរបបនេះពិតជាបានរក្សាពាក្យសន្យានោះមែន ។ សាមសិបឆ្នាំក្រោយមកប្រទេសកម្ពុជានៅតែមានការបាត់បង់ និងបែកបាក់ដដែល ។


មេឃុំជួបសំណេះសំណាលជាមួយ
ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកនៅនិវេសនដ្ឋានរបស់លោក

ការបែកបាក់របស់ប្រទេសកម្ពុជាមិនមែនត្រឹមតែផ្នែកនយោបាយ និងសេដ្ឋកិច្ចតែប៉ុណ្ណោះទេ ប៉ុន្តែបានប៉ះពាល់ដល់ទឹកចិត្ត និងស្មារតីផងដែរ ។ គុណវិបត្តិនៃប្រទេសកម្ពុជានៅក្នុងសម័យនេះ រាប់តាំងពីការជួយជូរមនុស្សរហូតដល់ការជួញដូរថ្នាំញៀន ពីការឆក់ប្លន់ធនធានធម្មជាតិនិងសម្បត្តិវប្បធម៌រហូតដល់អំពើពុករលួយដែលរីករាលដាលនៅគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋាភិបាល គុណវិបត្តិទាំងនេះកាន់តែធ្ងន់ធ្ងរទៅៗ ដោយសារតែការខកខានរបស់យើងក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកជំនុំជម្រះទោស ។ វប្បធម៌និទណ្ឌភាពដែលយើងឃើញមាននៅទូទាំងប្រទេសកម្ពុជាសព្វថ្ងៃនេះ មានប្រភពពីជំនឿរបស់ប្រជាជនកម្ពុជាដែលជឿថា វាមិនដែលមានបទឧក្រិដ្ឋណាធំធេងដែលត្រូវតែផ្តន្ទាទោសនោះទេ និងថាអ្វីៗដែលប្រជាពលរដ្ឋកម្ពុជាធ្វើគឺអាចទទួលយកបានទាំងអស់ ព្រោះថា ទង្វើទាំងនោះ បើទោះបីជាអាក្រក់យ៉ាងណាក៏មិនដល់ថ្នាក់អាក្រក់ជាងអ្វីដែលរបបខ្មែរក្រហមបានប្រព្រឹត្តឡើយ ហើយអ្នកប្រព្រឹត្តទាំងនោះនៅតែរួចខ្លួនពីសំណាញ់ច្បាប់ ។

វានឹងនៅតែមានឧបសគ្គធំៗទៅលើដំណើរជឿនលឿនទៅមុខ និងកំណែទម្រង់របស់ប្រទេសកម្ពុជា លុះត្រាតែមានការផ្តល់យុត្តិធម៌នៅក្នុងកម្រិតណាមួយ ។ ប៉ុន្តែឧក្រិដ្ឋជនទាំងនោះកាន់តែមានវ័យចាស់ជរាណាស់ហើយ ហើយមួយទសវត្សរ៍ទៀត អ្នកទាំងនេះទំនងជាស្លាប់យ៉ាងស្ងប់ស្ងាត់និងដោយសុខសាន្ត ។ តាម៉ុក ទើបតែស្លាប់សប្តាហ៍មុននេះ ។ ការស្លាប់នេះ ដែលបានឆក់យករួចហើយនូវជីវិតនិងសុភមង្គលពីប្រជាជនខ្មែរជាច្រើន នៅពេលនេះទៀតបានឆក់យកពីពួកគេម្តងទៀតនូវឱកាសទទួលបានយុត្តិធម៌ ។ តើការស្រេកឃ្លានយុត្តិធម៌របស់យើងអាចបំពេញយ៉ាងដូចម្តេច បើតុលាការមិនបន្តការងាររបស់ខ្លួន? បើតុលាការនៅតែពន្យារពេលតទៅទៀត? បើជនដៃដល់នៅតែអាចរស់នៅរហូតដល់ចាស់ស្លាប់ដោយសុខសាន្ត ដោយមិនបានទទួលស្គាល់ចំពោះអំពើឧក្រិដ្ឋរបស់ខ្លួន ឬទទួលខុសត្រូវចំពោះអំពើដ៏គួរឲ្យខ្លាចដែលពួកគេប្រព្រឹត្តមកលើប្រជាជនកម្ពុជាដែលជាជនរួមជាតិរបស់ពួកគេ?

អ្នកទាំងឡាយដែលបានស្លាប់ និងអ្នកទាំងឡាយដែលបានរងនូវការឈឺចាប់ ៈ ការស្លាប់ និងការឈឺចាប់របស់ពួកគេត្រូវការយុត្តិធម៌និងភាពស្ងប់ស្ងាត់ ។ ជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍សមនឹងទទួលបានយុត្តិធម៌ ហើយជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍ទាមទារយុត្តិធម៌ ។ ប្រជាជនកម្ពុជាត្រូវការបំពេញសេចក្តីស្រេកឃ្លានយុត្តិធម៌របស់ពួកគេ ។